ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា

សំណុំរឿងរដ្ឋប្បវេណី
លេខ : ២២៩
ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២

សាលដីកា
លេខ : ៥៦៣ (គ)
ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣ ។

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោកស្រី ជាចៅក្រម

លោក

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

-ដើមចោទឈ្មោះ [redacted] កាសល្យ និងឈ្មោះ [redacted] សុខា (ម្ចាស់បណ្តឹងសាទុក្ខ) មានទីលំនៅភូមិស្វាយក្រវ៉ាន់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

-ចុងចម្លើយឈ្មោះ [redacted] ជា និងប្តីឈ្មោះ [redacted] បាន (ម្ចាស់បណ្តឹងសាទុក្ខ) មានទីលំនៅភូមិផ្សារសាមគ្គី សង្កាត់កណ្តាលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

**<u>កម្មវត្ថុបណ្តឹង</u>** ៖ - ប្តឹងទាមទារប្រាក់ចំនួន ១២.០០០ ដុល្លារ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ការប្រាក់ ៦០០ ដុល្លារ (ប្រាំមួយរយដុល្លារអាមេរិក) ក្នុងមួយខែ រហូតដល់សងប្រាក់គ្រប់ចំនួន ដូចមាននៅក្នុងកិច្ចសន្យាខ្ចីប្រាក់ កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ពីចុងចម្លើយ ។
- សុំអោយរឹបអូសផ្ទះ និងដីដែលដាក់បញ្ចាំ ។
- សុំទាមទារការខាតបង់ និងការយឺតយ៉ាវចំនួន ៤.០០០ ដុល្លារ (បួនពាន់ដុល្លារអាមេរិក) ។
- សុំអោយភាគីចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។


មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia
Scanned with CamScanner

# អំពីអង្គហេតុ និង ចំណុចវិវាទ

## ក - <u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ</u>

-ឈ្មោះ [redacted] សុខា និងប្តីឈ្មោះ [redacted] កោសល្យ បានថ្លែងការណ៍ថា ដំបូងឈ្មោះ [redacted] ផា បានខ្ចីប្រាក់ពីបងស្រីរបស់ខ្លួនឈ្មោះ [redacted] សុជា បន្ទាប់មកឈ្មោះ [redacted] សុជា ប្រាប់អោយមកជួបខ្លួនទើបឈ្មោះ [redacted] ផា បានមកជួបខ្លួន ហើយបានព្រមព្រៀងធ្វើកិច្ចសន្យាខ្ចីប្រាក់ចំនួន ១២.០០០ ដុល្លារ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ដោយព្រមព្រៀងអោយការប្រាក់ ៦០០ ដុល្លារ (ប្រាំមួយរយដុល្លារអាមេរិក) ក្នុង ១ ខែ ហើយក៏បានចុះកិច្ចសន្យានៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ដោយមានសាក្សីមេភូមិ មេឃុំដឹងឮទៀតផង ក្រោយពីឈ្មោះ [redacted] ផា បានទទួលប្រាក់ពីខ្លួនហើយ ឈ្មោះ [redacted] ផា មិនបានអនុវត្តតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ដោយមិនបានបង់ការប្រាក់ និងប្រាក់ដើមមកអោយខ្លួនតាមកិច្ចសន្យាខ្ចីប្រាក់រហូតមកដល់សព្វថ្ងៃនេះ។ សំណូមពរ សុំទាមទារប្រាក់ដើមចំនួន ១២.០០០ ដុល្លារ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ការប្រាក់ ៦០០ ដុល្លារ (ប្រាំមួយរយដុល្លារអាមេរិក) ក្នុង ១ ខែ និងទាមទារការយឺតយ៉ាវចំនួន ៤.០០០ ដុល្លារ (បួនពាន់ដុល្លារអាមេរិក) ហើយបើឈ្មោះ [redacted] ផា គ្មានប្រាក់សងទេ គឺសុំរឹបអូសផ្ទះ និងដីដែលបានដាក់បញ្ចាំ។

ភាគីចុងចម្លើយឈ្មោះ [redacted] ផា ដែលមានលោក [redacted] ពួង ជាមេធាវីតំណាងដោយអាណត្តិ បានថ្លែងថា កូនក្តីខ្លួនពិតជាបានខ្ចីប្រាក់ពីភាគីដើមចោទចំនួន ១២.០០០ ដុល្លារ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ហើយព្រមព្រៀងបង់ការប្រាក់ ៦០០ ដុល្លារ (ប្រាំមួយរយដុល្លារអាមេរិក) ក្នុង ១ ខែ មាននៅក្នុងកិច្ចសន្យាចងការប្រាក់អោយទៅដើមចោទក្នុង ១ ថ្ងៃ ២០ ដុល្លារអាមេរិក សរុបទាំងអស់ចំនួន ១.៥២០ ដុល្លារ (មួយពាន់ប្រាំរយម្ភៃដុល្លារអាមេរិក) រួចហើយ ដូច្នេះ ក្នុងរឿងក្តីនេះ ខ្លួនទទួលស្គាល់ប្រាក់ដើមចំនួន ១២.០០០ ដុល្លារ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ហើយសុំអោយគិតការប្រាក់ទៅតាមច្បាប់កំណត់ដោយគិតចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៩។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០២ "ធ" ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-បង្គាប់ឲ្យឈ្មោះ [redacted] ផា និងឈ្មោះ [redacted] បាន សងប្រាក់ដើមចំនួន ១២.០០០ ដុល្លារ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ឲ្យទៅភាគីដើមចោទឈ្មោះ [redacted] សុខា និងឈ្មោះ [redacted]-កោសល្យ និងការប្រាក់ ៥ ភាគរយ ក្នុង ១ ឆ្នាំ គិតចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន និងការយឺតយ៉ាវចំនួន ៦.០០០.០០០ រៀល (ប្រាំមួយលានរៀល) គត់។ ករណីគ្មានប្រាក់សង ត្រូវរឹបអូសផ្ទះ និងដី ដែលបានដាក់បញ្ចាំក្នុងកិច្ចសន្យាចងការប្រាក់។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

៣-សាលក្រមនេះ ទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០។

៤-បើភាគីណាមិនសុខចិត្តនឹងសាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃបានទទួលអនុសារសាលក្រមនេះ។



១៩

Scanned with CamScanner

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ផា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០២ "ធ" ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចទី ១ នៃសេចក្តីសំរេចបញ្ចប់។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៦ ក្រ៥.ប ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយ។

២-តម្កល់សាលក្រមដើមរបស់សាលាដំបូងខេត្តកំពង់ស្ពឺ តែត្រូវកែប្រែលើប្រាក់ដើម និងការប្រាក់សំរេចថា បង្គាប់ឲ្យ [redacted] ផា និងឈ្មោះ [redacted] បាន សងប្រាក់ដើមចំនួន ១០.៤៨០ ដុល្លារ (មួយម៉ឺនបួនរយប៉ែតសិបដុល្លារអាមេរិក) ឲ្យនៅដើមចោទឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] កុសល្យ និងការប្រាក់ ៥% ក្នុង ១ ឆ្នាំ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ រហូតសងគ្រប់។ ក្រៅពីនេះរក្សាទុកដដែល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុកចុងចម្លើយ។

៤-សាលដីកាប្រកាសជាសាធារណៈ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ បើកផ្លូវប្តឹងសាទុក្ខក្នុងអំឡុងពេល ១ ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

-បានឃើញបណ្តឹងសាទុក្ខលេខ ៣៤០ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុខា ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ០៦ ក្រ៥.ប ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី ២ នៃសាលដីកា ដែលកែប្រែប្រាក់ដើមពី ១២.០០០ ដុល្លារ (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) មកត្រឹម ១០.៤៨០ ដុល្លារ (មួយម៉ឺនសូន្យពាន់បួនរយប៉ែតសិបដុល្លារ)។

-បានឃើញបណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ផា ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ០៦ ក្រ៥.ប ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

**ខ - អំពីសេចក្តីថ្លែងការណ៍របស់គូភាគី**

-អ្នកស្រី [redacted] ផា ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើការអះអាងថា ៖

ខ្លួនបានខ្ចីប្រាក់គាត់ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ មែន ចំនួន ១២.០០០ ដុល្លារ ហើយដាក់ប្លង់បញ្ចាំ និងបានធ្វើកិច្ចសន្យាត្រឹមត្រូវ។ ខ្លួនសងគាត់បាន ១.៥២០ ដុល្លារអាមេរិក ហើយខ្លួនជំពាក់ប្រាក់គាត់ ១២.០០០ ដុល្លារអាមេរិក ខ្លួនជំពាក់លុយត្រូវសងលុយ មិនឲ្យរឹបអូសយកផ្ទះខ្លួនទេ ខ្លួនសុំសងតាមលទ្ធភាព។

-អ្នកស្រី [redacted] សុខា ជាម្ចាស់បណ្ដឹងសាទុក្ខ បានធ្វើការអះអាងថា ៖

ខ្លួនមិនអាចឱ្យគាត់សងខ្លួនតាមលទ្ធភាពបានទេ ហើយគាត់មិនទាន់ធ្លាក់លួងសងលុយខ្លួនដល់ ១.៥២០ ដុល្លារអាមេរិក ដោយគ្មានឯកសារនោះទេ។

សំណូមពរ : សុំតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ៣៤០ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុខា និងបណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ផា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលក្រមដើមរបស់សាលាដំបូងខេត្តកំពង់ស្ពឺ តែត្រូវកែប្រែលើប្រាក់ដើម និងការប្រាក់ ដោយសម្រេចថា បង្គាប់អោយឈ្មោះ [redacted] ផា និងឈ្មោះ [redacted] បាន សងប្រាក់ដើមចំនួន ១០.៤៨០ ដុល្លារ (មួយម៉ឺនបួនរយប៉ែតសិបដុល្លារអាមេរិក) អោយទៅដើមចោទឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] កុសល្យ និងការប្រាក់ ៥% ក្នុងមួយឆ្នាំ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ រហូតសងគ្រប់។ ក្រៅពីនេះរក្សាទុកដដែលនោះ គឺពុំមានមូលដ្ឋានត្រឹមត្រូវទេ ពីព្រោះថា ដើមចោទពុំបានទទួលស្គាល់ថា ចុងចម្លើយបានសងការប្រាក់ ២ ខែ ២០ ថ្ងៃ ស្មើនឹង ១.៥២០ ដុល្លារអាមេរិកនោះទេ ហើយក៏ពុំមានភស្តុតាងជាឯកសារណាដែលបញ្ជាក់ថា ចុងចម្លើយបានសងនូវចំនួនទឹកប្រាក់នេះដែរ ប៉ុន្តែការដែលខ្លួនជាដើមចោទយល់ព្រមមិនប្តឹងឧទ្ធរណ៍នឹងការសំរេចសេចក្តីរបស់សាលាដំបូងក្នុងការគិតការប្រាក់ ៥ ភាគរយ តាមច្បាប់ គិតពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៩ នោះ ពីព្រោះតែ ដើម្បីកុំឱ្យមានការប្តឹងផ្តល់វែងឆ្ងាយតែប៉ុណ្ណោះ តែផ្ទុយទៅវិញ ចុងចម្លើយនៅតែប្តឹងបន្តទៀត។

-យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍យកប្រាក់ដើមចំនួន ១២.០០០ ដុល្លារអាមេរិច ដកនឹងទឹកប្រាក់ ១.៥២០ ដុល្លារអាមេរិក ដើម្បីជាមូលដ្ឋានក្នុងការគិតប្រាក់ដើមតែម្តងនោះ គឺផ្ទុយនឹងមាត្រា ៦០ នៃក្រិត្យច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា។

-យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ០៦ "ក្រ៥.ប" ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវតាមគតិច្បាប់ទេ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៤០ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុខា។

-បដិសេធបណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ផា។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ០៦ “ក្រ៥.ប” ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ទាំងមូល។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ២២៩ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសាជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ចុងចម្លើយ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣។

-ឯកឧត្តម [redacted] ប្រធាន

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោកស្រី [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤

ប្រធាន

[redacted]